# តំបន់ទេសចរណ៍
# ភាគខាងជើង
# ខេត្តតាកែវ

និត កុសល

# អារម្ភកថា

សូមជម្រាបសួរ បងប្អូនប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិជាទីមេត្រី!

កូនសៀវភៅតូច ដែលលោកអ្នកកំពុងតែកាន់អានក្នុងដៃនេះ មាន ចំណងជើងថា "**តំបន់ទេសចរណ៍ភាគខាងជើងឥឡូវមខេត្តតាកែវ**" ដែលនឹងនាំ ផ្លូវលោកអ្នកឲ្យស្គាល់តំបន់ទេសចរណ៍មួយចំនួន ដូចជា ប្រាសាទតាព្រហ្ម ប្រាសាទយាយពៅ ទន្លេបាទី ប្រាសាទនាងខ្មៅ ប្រាសាទភ្នំជីសូរ ប្រាសាទ សែននិមល និងប្រាសាទភូវាំង។

ការសម្រេចចិត្តចុះទៅសិក្សាស្រាវជ្រាវផ្ទាល់ដល់កន្លែង និងការ ប្រមូលផ្តុំទិន្នន័យពីប្រភពផ្សេងៗ ចងក្រងជាឯកសារថ្មីនេះ គឺដើម្បីផ្តល់ភាព ងាយស្រួលដល់អ្នកទេសចរណ៍ និងចូលរួមផ្សព្វផ្សាយឲ្យភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិអញ្ជើញមកទស្សនាកំសាន្តអារម្មណ៍នៅទីនេះ។ នៅពេលដែល មានភ្ញៀវទេសចរណ៍មកទស្សនាតំបន់ទាំងនេះកាន់តែច្រើន នោះនឹងធ្វើឲ្យ កម្រិតជីវភាពប្រជាពលរដ្ឋនៅតំបន់នេះ បានល្អប្រសើរជាងមុន។ ក្នុងកូន សៀវភៅតូចនេះ ក៏បានរៀបរាប់អំពីវិធីសាស្ត្រខ្លះៗ ដើម្បីទាក់ទាញភ្ញៀវ ទេសចរណ៍ឲ្យមកទស្សនាទីនេះ និងការទុកដាក់សំរាមឲ្យបានត្រឹមត្រូវ រួមទាំង របៀបអភិវឌ្ឍន៍ទីនេះ ឲ្យមានស្តង់ដា ឲ្យស្រប នឹងតម្រូវការរបស់អ្នក ទេសចរណ៍សម័យថ្មី។

យើងខ្ញុំសាទរ និង រីករាយរាល់ការ រិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យ អត្ថបទនេះ មានភាពសុក្រឹតស្រប នឹងស្ថានភាព ជាក់ស្តែង និង កត្តាប្រវត្តិសាស្រ្តពិត។

យើងខ្ញុំសូមពរបងប្អូនប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិ សប្បាយរីករាយ ក្នុង ដំណើរកំសាន្ត មកភាគខាងជើង ទីរួមខេត្តតាកែវ។

ភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៧

**និត កុសល**

សិស្សនិស្សិតវិទ្យាសាស្រ្តសេដ្ឋកិច្ច

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណអស់ពីដួងចិត្តជូនចំពោះ បុព្វបុរសដូនតាខ្មែរ ដែលលោកបានសាងសង់ប្រាង្គប្រាសាទ ដ៏ស្រស់ស្អាតប្រណិតថ្លាថ្លៃមិនអាចកាត់ថ្លៃបាន សម្រាប់ប្រជាជាតិខ្មែរ។ ប្រាង្គប្រាសាទទាំងអស់ ដែលលោកបានកសាងកាលពីសម័យនោះ បាននឹងកំពុងស្វែងរកប្រាក់ចំណូលជូនជាតិ និងប្រជាពលរដ្ឋកម្ពុជាយ៉ាងច្រើនសម្បើម។

ខ្ញុំសូមថ្លែងអំណរគុណ លោកអាចារ្យ វត្តគិរីសោភ័ណ (ភ្នំជីសូរ) ទាំងបីនាក់ ដែលលោកបាននិទានរឿងរ៉ាវប្រាសាទភ្នំជីសូរប្រាប់ខ្ញុំ ដើម្បីបានជាទិន្នន័យក្នុងការចងក្រងឯកសារនេះឡើង។

ខ្ញុំសូមថ្លែងអំណរគុណលោក អ៊ំប្រុសអ្នកឃ្លាលគោទាំងបីនាក់ ដែលបាននាំផ្លូវខ្ញុំមកប្រាសាទភ្នំវាំង ហើយបាននិទាន ប្រវត្តិប្រាសាទនេះប្រាប់ខ្ញុំ ដើម្បីបានជាទិន្នន័យក្នុងការចងក្រងនេះ។

ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះមាតាបិតារបស់ខ្ញុំ ដែលបានចិញ្ចឹមបីបាច់ និងអប់រំរូបខ្ញុំ។

# មាតិកា

១. ទីតាំងខ្លះខេត្តតាកែវ ........ 5
២. ប្រាសាទយាយពៅ ........ 7
៣. ប្រាសាទតាព្រហ្ម ........ 9
៤ .ទន្លេបាទី ........ 12
៥. ប្រាសាទនាងខ្មៅ ........ 15
៦. ប្រាសាទភ្នំជីសូរ ........ 15
៧. ប្រាសាទសែននិមល ........ 24
៨. ប្រាសាទតូទាំង ........ 26
៩. បញ្ហាសកម្មមួយចំនួន ........ 29
៩.១. សំរាម និងថង់ប្លាស្ទិច ........ 30
ដំណោះស្រាយ ........ 30
៩.២. អ្នកសុំទាន ........ 31
ដំណោះស្រាយ ........ 33
១០. ឯកសារយោង ........ 34

## ១. ទីតាំងភូមិសាស្ត្រខេត្តតាកែវ

តាកែវគឺជាខេត្តមួយនៃប្រទេសកម្ពុជា។ ទីរួមខេត្តរបស់ខេត្តនេះគឺ **ក្រុងដូនកែវ**។ តាំងនៅភាគនិរតីនៃកម្ពុជា តាកែវជាប់ខេត្តកំពតនៅខាងលិច កំពង់ស្ពឺ នៅភាគពាយព្យ និង កណ្ដាល នៅភាគខាងជើង និង ខាងកើត។ ព្រំប្រទល់ខាងត្បូងរបស់ខេត្តនេះ គឺជា ព្រំដែនអន្តរជាតិជាមួយវៀតណាម។ ធ្វើដំណើរពីភ្នំពេញទៅកាន់ទីរួមលើកំណាត់ផ្លូវជាតិ **លេខ២** គេនឹងបាន ឃើញស្ថានភាពប្រជាពលរដ្ឋ ការប្រកបរបររកស៊ីរបស់ពួកគេនៅក្នុងខេត្ត នេះ។ មិនតែប៉ុណ្ណោះ គេក៏អាចធ្វើដំណើរតាមផ្លូវជាតិ **លេខ២** ផងដែរ ដែល មានចម្ងាយផ្លូវប្រហែល **៧៨ គីឡូម៉ែត្រ**។ សក្ដានុពលភាពសំខាន់ក្នុងខេត្ត នេះគឺវិស័យទេសចរ ដែលជាប្រភពចំណូលជូនរដ្ឋ និងអាចឱ្យប្រជាពលរដ្ឋ ទាញរកប្រយោជន៍ពីវិស័យនេះផងដែរ ។

តាកែវ ជាជម្រក នៃអារ្យធម៌ខ្មែរព្រោះថាខេត្តនេះជាខេត្ត មួយមាន វ័យចំណាស់ជាងគេបំផុត និងជាទីតាំងដើមនៃវប្បធម៌ខ្មែរផងដែរ។ខេត្តតាកែវជាខេត្តមួយមានវ័យចំណាស់ជាងគេ ក្នុងចំណោមខេត្តក្រុងទាំង ២៥ នៃ ព្រះរាជាណាចក្រ កម្ពុជា។ ហើយមានផ្ទៃដីសរុប **៣,៥៦២.៧០គីឡូម៉ែត្រការេ** ។ ទឹកដីដ៏យូរលង់នេះសំបូរទៅដោយធនធាន ប្រវត្តិសាស្ត្រ ជាច្រើនដែល ទាក់ទងនឹងសម័យអាណាចក្រភ្នំ និងសម័យចេនឡា ដោយមាន ប្រាសាទ បុរាណជាច្រើន រហូតដល់ **៣៤ប្រាសាទ**។ តំបន់ទាំងអស់នេះហើយ ដែល កំពុងបង្កួត និងទាក់ទាញអ្នកទេសចរជាតិ និងអន្តរជាតិទៅកម្សាន្តជាហូរហែ។

បច្ចុប្បន្ន ខេត្តតាកែវ ប្រាសាទ ដែល មានរូបរាងច្បាស់លាស់ចំនួន **៦កន្លែង** ដែលទាក់ទងនឹងប្រវត្តិសាស្ត្រដូចជា៖

- **ប្រាសាទភ្នំដា** ស្ថាបនាឡើងនៅក្នុងសតវត្សទី៦ស្ថិតនៅក្នុងស្រុកអង្គរបុរី។
- **ប្រាសាទបាយ៉ង** ស្ថាបនាឡើងក្នុងសតវត្សទី៧ ស្ថិតនៅលើកំពូលភ្នំ បាយ៉ង ស្រុកគិរីវង្ស។
- **ប្រាសាទនាងខ្មៅ** ស្ថាបនាឡើងក្នុងសតវត្សទី១០ ស្ថិតនៅក្នុងស្រុកសំរោង។
- **ប្រាសាទភ្នំជីសូរ** ស្ថាបនាឡើងក្នុងសតវត្សទី១១ ស្ថិតនៅលើកំពូលភ្នំជីសូរក្នុងស្រុកសំរោង។
- **ប្រាសាទភ្នំតាម៉ៅ** ស្ថាបនាឡើងក្នុងសតវត្សទី១១ ស្ថិតនៅក្នុង ស្រុកបាទី។
- **ប្រាសាទបាទី** ស្ថាបនាឡើងក្នុងសតវត្សទី១២ និងដើមសតវត្សទី១៣ ស្ថិតនៅក្នុងស្រុកបាទី។

ជាក់ស្តែងខេត្តនេះបានបន្សល់ទុកនូវកេរ្តិ៍ ដំណែលប្រាសាទបុរាណសំខាន់ៗមួយចំនួន ដែលមានអាយុកាលរាប់សតវត្សមកហើយ សម្រាប់ជាភស្តុតាងបង្ហាញពី ភាពរុងរឿងរីកចម្រើននៃខេត្តនេះក្នុងអតីតកាល។

## ២. ប្រាសាទយាយពៅ

ប្រាសាទយាយពៅ ស្ថិត នៅ ប្រហែលជា **១០០ម៉ែត្រ** ខាង ជើង ប្រាសាទ តាព្រហ្ម ។ តាមសិលាចារឹកបញ្ជាក់ថា ប្រាសាទនេះត្រូវបានសាងសង់ក្នុងរាជ**ព្រះបាទជ័យវរ្ម័នទី ៧** (១១៨១-១២១៨) ហើយស្ថិតនៅក្នុងរចនាបថបាយ័នសម្រាប់ឧទ្ទិសដល់ព្រហ្មញ្ញសាសនាផង និង ពុទ្ធសាសនាផង ។

បើតាមរឿងព្រេងដំណាលថា កាល ព្រះកេតុមាលា សោយរាជ្យ នៅឯអង្គរធំក៏ទ្រង់យាងមកត្រួតពិនិត្យរាស្ត្រនៅទីត្រង់ទន្លេបាទីនេះ ក៏ប្រទះឃើញនារីម្នាក់មានសម្រស់ស្រស់សោភាឈ្មោះ នាងពៅ ទ្រង់ក៏លើកនាងជាស្នំ ។ ក្រោយមកដោយត្រូវយាងទៅព្រះនគរវិញ ហើយដោយនាងពៅ មានទម្ងន់ផងនោះក៏យកទៅពុំបាន ។ក្រោយមកនាងពៅក៏សម្រាលបានកូនប្រុសម្នាក់ដាក់ឈ្មោះថា អង្គព្រហ្ម ។ កុមារ ព្រហ្ម លុះធំឡើងសួររកឪពុក ម្តាយក៏ប្រាប់តាមដំណើរហើយក៏ចេញទៅរកឪពុកដែលជាស្តេចនៅឯនគរធំ ។ លុះស្តេចជាឪពុកបានជ្រាបការណ៍អស់ហើយនោះ ក៏បញ្ជាឲ្យគេសង់ប្រាសាទមួយទុកឲ្យបុត្រ (ប្រាសាទតាព្រហ្មនៅសៀមរាបសព្វថ្ងៃ)។

ក្រោយមក អង្គព្រហ្ម ក៏ត្រឡប់មកស្រុកទន្លេបាទីវិញដោយបានងារជា ព្រះអជ្ជិត ថៅហ្វាយខែត្រស្រុកបាទី ។ អង្គព្រហ្ម ក៏សាងប្រាសាទ ២ មួយគឺប្រាសាទតាព្រហ្មសព្វថ្ងៃ និងមួយទៀតប្រាសាទយាយពៅសព្វថ្ងៃដែលទុកសម្រាប់ឲ្យម្តាយគោរពបូជា ។

ឯរឿងព្រេងមួយទៀតបានដំណាលថា ព្រះកេតុមាលា បានមកត្រួតពិនិត្យត្រង់ទន្លេបាទីនេះ ក៏ទៅប្រកួតចំបាប់នឹងនាងខ្មៅ (ប្រាសាទនាង

ខ្មៅ) ដែលប្រកាសថានរណាប្រកួតឈ្នះនាង នាងនឹងព្រមយកធ្វើប្ដី ។ លុះព្រះកេតុមាលា ឈ្នះហើយ នាងក៏ព្រមយកជាស្វាមី ។

ដំណាលសាច់រឿងក៏ដូចរឿងខាងលើ តែប្លែកថា អង្គព្រហ្ម ពេលត្រឡប់មកវិញក៏ចាប់ចិត្តស្រលាញ់កូនក្រមុំគេម្នាក់ឈ្មោះ នាងពៅ ហើយក៏ចូលស្ដីដណ្ដឹងដោយមានការភ្នាល់គ្នាសាងប្រាសាទ ។ ក្រុមស្រីឆ្លាតជាងក៏ប្រើល្បិចបង្ហូតគោម (ល្បិចដដែលៗ) ដែលប្រជាជននៅទីនោះដំណាលមកទល់សព្វថ្ងៃថា ដោយខាងប្រុសចាញ់បានជាគេឃើញមានថ្មនៅរាយពាសពេញប្រាសាទតាព្រហ្ម ឯប្រាសាទយាយពៅធ្វើរួចបានយ៉ាងល្អ ។

រឿងព្រេងទាំង ២ នេះខុសគ្នាត្រង់ដំណាលមួយថា ជាម្ដាយ មួយថា ជាប្រពន្ធ ។

ប្រភពដដែលបន្តឲ្យដឹងទៀតថា ចំណែកប្រាសាទយាយពៅវិញ មានរាងជា ការ៉េបួនជ្រុងក្នុងប្រវែង **៧ x ៧ម៉ែត្រ** បែរមុខទៅទិសខាងកើត។ ប្រាសាទយាយពៅ ត្រូវបានកសាងឡើងដោយថ្មភក់នៅក្នុងសតវត្សទី១២។ ដោយឡែក ផ្អែកលើរឿងព្រេងបុរាណវិញ បាននិទានឲ្យដឹងថា ប្រាសាទតាព្រហ្ម និងប្រាសាទយាយពៅមានកំណើតឡើងទាក់ទងទៅនឹងរឿងព្រេងព្រះបាទកេតុមាលា ស្ដេចនៃមហានគរ ដែលមានសព្វព្រះរាជហឫទ័យទៅលើនាងពៅកូនក្រមុំអ្នកស្រុកបាទីសព្វថ្ងៃរហូតមានបុត្រមួយព្រះអង្គព្រះនាម ព្រហ្ម ហើយទ្រង់បានក្លាយជាស្ដេចក្រាញ់នៅតំបន់នេះទើបកសាងប្រាសាទយាយពៅ ដើម្បីថ្វាយមាតា និងកសាងប្រាសាទតាព្រហ្មសម្រាប់ព្រះអង្គគង់នៅផ្ទាល់តែម្ដង។

## ៣. ប្រាសាទតាព្រហ្ម

ប្រាសាទតាព្រហ្ម ស្ថិតនៅក្នុងរមណីយដ្ឋានទន្លេបាទីក្នុងភូមិសាស្រ្ត ភូមិថ្នល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ មានចម្ងាយ ៣៤គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិ **លេខ២**។ ប្រាសាទ នេះសង់ឡើងនៅសតវត្សរ៍ទី ១២ និង ដើមសតវត្សរ៍ទី ១៣ ពីឆ្នាំ ១១៨១ ដល់ឆ្នាំ ១២០១ ប្រកបដោយក្បូរក្បាច់រចនាដ៏វិចិត្រ ប្រហាក់ប្រហែលនឹងប្រាសាទតាព្រហ្មនៅខេត្តសៀមរាបដែរព្រោះស្ថាបត្យកម្មនេះស្ថិត នៅក្នុងរចនាបថបាយ័ន នារជ្ជកាល **ព្រះបាទជ័យវរ្ម័នទី៧** ដែលជាអធិរាជនៃចក្រភពកម្ពុជា។ បន្ទាប់ពីបញ្ចប់សឹកសង្គ្រាមជាមួយដែនដីចម្ប៉ារំដោះបានរាជធានីអង្គរ និងមាតុភូមិ ជាស្ថាពរមក **ព្រះបាទជ័យវរ្ម័នទី៧** ចាប់ផ្ដើមធ្វើការ បង្រួបបង្រួមជាតិតាមមាគ៌ាសន្តិភាពនូវភាវូបនីយកម្មដោយបន្សុីភ្ជាប់គ្នារវាងព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនា គោរពអាទិទេពទាំង៣ ។ ការបង្រួបបង្រួមនេះ ស្ដែងចេញ តាមរយៈសំណង់ប្រាសាទធំៗមានជាអាទិ៍ដូចជា ប្រាសាទបាយ័ន ប្រាសាទបន្ទាយក្ដី ប្រាសាទព្រះខ័ន ប្រាសាទបន្ទាយឆ្មារ ស្រះស្រង់ ប្រាសាទនាគព័ន្ធ ប្រាសាទតាសោម ប្រាសាទក្រោលគោ មហាកំពែងព័ទ្ធជុំវិញក្រុងអង្គរធំជាដើម។

ដោយឡែកប្រាសាទតាព្រហ្មទាំងពីរ នៅខេត្តសៀមរាប និងខេត្តតាកែវ ត្រូវបានស្ថាបនាឡើងដើម្បីឧទ្ទិសថ្វាយដល់ព្រះលោកេស្វរៈ និងយកធ្វើជាអារាមសម្រាប់ព្រះសង្ឃគង់នៅរហូត ដល់ប្រាសាទតាព្រហ្ម នៅតំបន់

---

តាមលោកតា សោម ដែលជាព្រឹទ្ធាចារ្យ និងជាឆ្មាំប្រាសាទបានរំលឹកពីប្រវត្តិនៃការកសាងប្រាសាទតាព្រហ្ម និងប្រាសាទយាយពៅតាមការនិយាយតៗគ្នាពីចាស់បុរាណ និងយោងតាមឯកសារដែលត្រូវបានស្រាវជ្រាវ។


ប្រាសាទតាព្រហ្ម


ប្រាសាទតាព្រហ្ម



ប្រាសាទតាព្រហ្ម



ដើមឈើ ក្នុងបរិវេនប្រាសាទតាព្រហ្ម

អង្គរមានឈ្មោះដើមថារាជវិហារ សម្រាប់ប្រាសាទតាព្រហ្មនៅទន្លេបាទី ទោះបីជាវិសាលភាពតូចជាងប្រាសាទទី១ នៅតំបន់អង្គរក្តី ក៏តឹកតាងបង្ហាញថាវាមានលក្ខណៈជាអារាម ឬជាបូជនីយដ្ឋានដ៏ពិសិដ្ឋ។ នៅទន្លេបាទីគ្មានភ្នំនៅជិតទេ តើដូនតាខ្មែរយកថ្មពីណាមកកសាងប្រាសាទ? សំណួរនេះ ត្រូវបានអ្នកប្រវត្តិសាស្ត្របកស្រាយថាគេត្រូវដឹកតាមរទេះ ដាក់ខ្នងដំរី ដាក់សំពៅ នាំយកផ្ទាំងថ្មទាំងនោះ ដែលរួមមានថ្មបាយក្រៀម និងថ្មភក់ ពីភ្នំឆ្ងាយៗ មកកសាងឲ្យកើតជាប្រាសាទនេះឡើង ដែលកំពូលប្រាសាទកណ្តាលមានកម្ពស់ដល់ទៅ១២ម៉ែត្រ ចំណែកបរិវេណកំពែង មាន**បណ្តោយ ១៥០ម៉ែត្រ** x **ទទឹង ៩៥ម៉ែត្រ**។ ប្រាសាទតាព្រហ្ម មានទំហំធំជាងដោយមានកំផែងខាងក្រៅ មានថែវ និងមានប្រាង្គកណ្តាលដែលមានទ្វារ ៤ ទិស ៦ ប្រាសាទយាយពៅ វិញមានតែមួយប្រាង្គហើយមានទ្វារចេញចូលតែទិសខាងកើត ។

ប្រាសាទតាព្រហ្មមានបណ្តោយ**ប្រវែង ៤២ម៉ែត្រ** x **ទទឹង ៣៦ម៉ែត្រ** និងកម្ពស់ ១១ម៉ែត្រមានថែវកំពែងគោបុរៈគូទឹកព័ទ្ធជុំវិញ ដែលបច្ចុប្បន្នទទួលរងនូវការខូចខាតយ៉ាងខ្លាំង។ ប្រាសាទនេះកសាងឡើងដោយថ្មភក់ និងថ្មបាយក្រៀម មានជញ្ជាំងខ័ណ្ឌជាបន្ទាប់ៗ ដែលផ្នែកខាងក្រៅលម្អដោយចម្លាក់លៀនបង្ហាញ ពី ទេពអប្សរក្នុងរឿងបែបព្រហ្មញ្ញ និយាយពីព្រះវិស្ណុថែរក្សាលោក និងផ្នែកខាងក្នុងមាន ៥បន្ទប់ មានព្រះពុទ្ធរូបក្នុង**សតវត្សទី១៣** ចំនួន២ បែរមុខទៅទិសខាងកើតនៅពីមុខរូបគ្រុឌ។

## ៤. ទន្លេបាទី

រមណីយដ្ឋានទន្លេបាទី ស្ថិតនៅក្នុងភូមិថ្នាល ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ក្នុងរយៈចម្ងាយប្រហែលជា ៤០ គ.ម ពីទីក្រុងភ្នំពេញ ។ ដោយធ្វើដំណើរពីភ្នំពេញ យើងនឹងបានឃើញស្លាកប៉ាណូដ៏ធំលើកឡើងនៅខាង

## តំបន់ទេសចរណ៍ភាគខាងជើងខេត្តតាកែវ

ស្ពាំដៃយើងបញ្ឈាក់ថាដល់ផ្លូវបត់ទៅរមណីយដ្ឋាននេះហើយ ដែលមានរយៈចម្ងាយ **៤គីឡូម៉ែត្រ** ដោយធ្វើដំណើរតាមផ្លូវដី ។

រមណីយដ្ឋាននេះ គឺជាបឹងមួយដែលមានទឹកទាំងប្រាំងវស្សា ដែលភ្ញៀវទេសចរណ៍អាចជួលតូបនៅមាត់ទឹកអង្គុយលេងកម្សាន្ត ឬក៏ស្ទូចត្រីជាដើម ។ ទន្លេបាទី មានភាពស្រស់ស្អាត បានទាក់ទងភ្ញៀវទេសចរណ៍ជនជាតិខ្មែរយ៉ាងច្រើនកោះគរ ប៉ុន្តែមិនឃើញមានភ្ញៀវបរទេសទៅទស្សនាកំសាន្តទេ។ មានតូបលក់អាហារជាច្រើនតាមបណ្តាយមាត់ទន្លេ ភ្ញៀវទេសចរណ៍អាចចុះហែរទឹកលេងកំសាន្តដោយសប្បាយរីករាយ។ នៅខែប្រាំងទន្លេបាទីនេះ មិនសម្បូរទឹកទេ ដូច្នេះ ជាហេតុនាំឲ្យ មិនសូវ មានអ្នកទេសចរណ៍ទៅទស្សនាលេងច្រើននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយអាកាសធាតុនៅទីនេះក្នុងខែប្រាំង មិនចាញ់ខែវស្សាប៉ុន្មាននោះទេ ពេលលោកអ្នកមកដល់ទីនេះអារម្មណ៍លោកអ្នកនឹងស្រស់ថ្លា រសាត់បាត់អស់ទុក្ខសោកសៅទាំងឡាយពីក្នុងខ្លួន។

ក្រៅពីមាត់បឹងធម្មជាតិ ដែលភ្ញៀវទេសចរតែងតែអង្គុយសម្រាកកាយ ស្រូបខ្យល់អាកាសបរិសុទ្ធ និងទទួលទានអាហារប្រចាំតំបន់របស់អ្នកស្រុក នៅរមណីយដ្ឋានទន្លេបាទី ក៏មាន បន្សល់ទុកកេរ្តិ៍ដំណែលប្រាសាទបុរាណ ដែលមានអាយុកាលរាប់ពាន់ឆ្នាំ។




ទន្លេបាទី


ទន្លេបាទី

## ៥. ប្រាសាទនាងខ្មៅ

ប្រាសាទនាងខ្មៅ ស្ថិត ក្នុងវត្តបុរាណនិវេសន៍ (ប្រាសាទនាងខ្មៅ) ដែលជាប់នឹងព្រះវិហារថ្មីតែម្តង។ លោកអ្នកទស្សនាប្រាកដប្រាសាទនេះរួចអាចអង្គុយ លេងកំសាន្តអារម្មណ៍ក្នុងបរិវេទ វត្តប្រាសាទនាងខ្មៅនេះ ដោយរីករាយ។


ប្រាសាទនាងខ្មៅ


ប្រាសាទនាងខ្មៅ

## ៦. ប្រាសាទភ្នំជីសូរ

ភ្នំជីសូរ ជាភ្នំធម្មជាតិដែលមានរយៈកម្ពស់ ១៣៣ ម៉ែត្រ ស្ថិតនៅក្នុងទីតាំងភូមិស្លា ឃុំរវៀង ស្រុកសំរោង ចម្ងាយ៦២គីឡូម៉ែត្រពីទីក្រុងភ្នំពេញ កាត់តាមស្រុក បាទី និងវត្តប្រាសាទនាងខ្មៅក្នុងស្រុកសំរោង តាមផ្លូវជាតិលេខ២ រួចបត់ចូលតាមផ្លូវលំតូចមួយប្រមាណ **៥គីឡូម៉ែត្រ** ទៀត។ ប៉ុន្តែប្រសិនជាធ្វើដំណើរពីទីរួមខេត្តតាកែវវិញ គេត្រូវចំណាយពេលប្រមាណ **៣០នាទី** លើកំណាត់ផ្លូវ **២៧គីឡូម៉ែត្រ**។ នៅលើខ្នងភ្នំជីសូរ នៅទិសខាងកើតលើកំពូលភ្នំមាន ប្រាសាទបូរាណដ៏ធំមួយឈ្មោះថា ប្រាសាទភ្នំជីសូរ ដែលសាងសង់ឡើងនៅកំឡុង ឆ្នាំ **១០០២-១០៥០ នៃគ.ស** ដោយព្រះបាទសូរ្យវរ្ម័នទី១ ស្ថិតនៅក្នុងរចនាបថបាពួនសម្រាប់ឧទ្ទិសបូជាថ្វាយចំពោះព្រហ្មញ្ញសាសនា។

ប្រាសាទនេះមានឈ្មោះដើមថា ស្រីសុរិយបវត៌ ដែលមានន័យថា ភ្នំនៃព្រះសុរិយា ។

ប្រាសាទនេះសាងសង់ពីថ្មភក់ និង ឥដ្ឋ មានតួប្រាង្គទាំងអស់ ៦ (គួរតែជាលេខសេស) មាន**ទំហំ៦០×៥០ម៉ែត្រ** មានថែវពីរជាន់ ប្រកបដោយក្បូរក្បាច់រចនារស់រវើកនៅតាមផ្ដែ និងសសរពេជ្រ។ ឯនៅខាងកើតប្រាសាទចុះតាមជណ្ដើរបុរាណមានប្រាសាទ ២ ទៀតដែលមានរាងជាកាកបាទ មួយឈ្មោះថា ***សែននិមល*** ដែលខូចខាតបាក់បែងអស់ហើយ និងហួសទៅឆ្ងាយទៀតហៅថា ***សែនរាំង*** ឬ ***សែនភូរាំង*** ដែលនៅគង់វង្សល្អ ប៉ុន្តែបច្ចុប្បន្នយើងអាចឃើញមានសាលាមួយធ្វើពីស៊ីម៉ង់ដែលមានតម្កល់ព្រះពុទ្ធរូបចូលនិព្វានមួយនៅកណ្ដាលប្រាង្គនោះ ។ហួសពី សែនរាំង ទៅទៀតយើងទៅដល់ ទន្លេអុំ ដែលនិយាយឲ្យចំជាបារាយណ៍ ។

ភ្ញៀវទេសចរអាចធ្វើ ដំណើរទៅកាន់ទីប្រាសាទតាមជណ្ដើរថ្មខាងលិចដែលមាន៣៩០កាំ ឬជណ្ដើរខាងត្បូងដែលមាន៤០៨កាំ។ ថ្វីត្បិតតែ

## តំបន់ទេសចរណ៍ភាគខាងជើងខេត្តតាកែវ

មួយភាគធំនៃប្រាសាទនេះត្រូវបានខូចខាតអស់ក៏ដោយ ប៉ុន្តែវាមានលក្ខណៈល្អផ្តាច់លើសប្រាសាទនានា នៅក្នុងតំបន់នេះ ជាហេតុធ្វើឲ្យ អ្នកទេសចរ និងអ្នកសិក្សាចូលចិត្តធ្វើដំណើរកំសាន្តមកកាន់ទីនេះ។ ក្រៅពីការទស្សនាប្រាសាទ គេក៏អាចគយគន់ទេសភាពវាលស្រែ ដ៏ស្រស់ត្រកាលពីលើកំពូលភ្នំជីសូរផង ដែរ។ ទស្សនីយភាពទាំងនេះបានទាក់ទាញភ្ញៀវទេសចរឱ្យចូលមកទស្សនាទីនេះ កាន់តែច្រើនឡើងៗ ជាពិសេសថ្ងៃបុណ្យ និងថ្ងៃឈប់សម្រាក។



ប្រាសាទជីសូរ

តាមឯកសារបានបង្ហាញថា នៅពីខាងត្បូង ភ្នំជីសូរនេះ មានរូងធម្មជាតិ មួយឈ្មោះ រូងវិមានច័ន្ទ ជាទីស្ងាត់ជ្រងំសម្រាប់ពួកតាបសឥសីធ្វើចង្រ្កមភាវនា ប៉ុន្តែកំឡុងពេលដែលប្រទេសយើងជួបប្រទះសង្រ្គាមពុំរ៉ៃ មានការទម្លាក់គ្រាប់ផ្ទុះ ជេរុងៗ ធ្វើឱ្យរូងនេះត្រូវបិទជិតដោយ ថ្មធំៗ មិនអាចចូលរួច។

នៅលើកំពូលភ្នំជីសូរ មានអ្នកលក់ដូរភាគច្រើនពួកគាត់លក់ទឹកកកឈូស និងនំកញ្ចប់មានតូបមិនជាង ១០ តូបទេ ចំណែកឯតម្លៃវិញគឺសមរម្យ។ ភ្ញៀវទេសចរណ៍ដែលមកទស្សនាប្រាង្គប្រាសាទលើកំពូលភ្នំនេះ ភាគច្រើនជាក្មេងៗ មានវ័យក្រោម ២០ឆ្នាំ ដែលពួកគេមានទីលំនៅក្បែរៗជើងភ្នំ ឬទីលំនៅក្នុងខេត្តតាកែវនេះផ្ទាល់ ដូចប្អូនស្រីម្នាក់ គាត់បានលើកឡើងថា ក្នុងមួយសប្តាហ៍គាត់មកទស្សនា និងស្រូបយកខ្យល់អាកាសនៅទីនេះម្តង។ ចំណែក ភ្ញៀវទេសចរណ៍បរទេសវិញ ក៏មាន ច្រើន គួរសម ដែរ។ ក្រៅពីទស្សនាប្រាង្គប្រាសាទលោកអ្នកអាចមើលទេសភាពដ៏ស្រស់ត្រកាលនៃខេត្តតាកែវពីលើភ្នំ និងអាចទស្សនាព្រះវិហារព្រះពុទ្ធសាសនាក្នុងបរិវាទវត្តគិរីសោភ័ណ (ភ្នំជីសូរ) នេះដោយរីករាយ។

បើតាមរឿងព្រេងដំណាលថា មានព្រះមហាក្សត្រមួយអង្គព្រះនាមសុរិយាទេវង្ស មានរិទ្ធិអំណាចយ៉ាងខ្លាំងក្លាសោយរាជ្យនៅលើភ្នំជីសូរ ។ ព្រះមហេសីទ្រង់ប្រសូតបានព្រះរាជបុត្រមួយអង្គគួរឲ្យស្រលាញ់ ។

ព្រះរាជាក៏ធ្វើពិធីបង្កក់ព្រះរាជបុត្រ ហើយអញ្ជើញព្រាហ្មណ៍ជាច្រើនអ្នកមកប្រោះព្រំចម្រើនពរឲ្យព្រះរាជបុត្រ ។ ក្នុងចំណោមព្រាហ្មណ៍ទាំងអស់ មានព្រាហ្មណ៍ម្នាក់ឲ្យពរប្លែកជាងគេដោយថា ៖

- សូមឲ្យមានកម្លាំងដូចស្រមោច
- សូមឲ្យមានរិទ្ធិដូចខ្មោច

- សូមឲ្យមានចិត្តដាច់ដូចមនុស្សស្រី

ព្រះរាជាខ្វាល់ជាងខ្លាំងចំពោះពរដ៏ចម្លែកនេះ តែព្រាហ្មណ៍នោះក៏សុំធ្វើឧទាហរណ៍បង្ហាញបញ្ជាក់ ។ ក្រោយពីបានបង្ហាញពិសោធន៍រួចហើយ ព្រះរាជាក៏យល់ថាព្រាហ្មណ៍នេះមានចំណេះដឹងខ្ពស់ជាងព្រាហ្មណ៍ឯទៀតក៏តែងតាំងព្រាហ្មណ៍នេះជាព្រាហ្មណ៍ធំលើគេ ទុកជាព្រះរាជគ្រូព្រះរាជបុត្រតរៀងទៅ ។

មានថែវ២ជាន់ព័ទ្ធជុំវិញ ដោយ ថែវទី២ មានទំហំតូចជាងថែវទី១ និងនៅចំកណ្តាល មានទីសក្ការៈមួយដែលសំខាន់ ហោយមានទ្វារឆ្លាស់ពីរខាងក្នុងមានបដិមាករមួយធ្វើអំពីឈើ។ ដោយឡែកទៀត គេប្រទះឃើញក្បាច់ចំលាក់យ៉ាងល្អប្រណិតនៅផ្តែរ និងសរសរពេជ្រ។



ប្រាសាទជីសូរ



ប្រាសាទជីសូរ



ប្រាសាទជីសូរ

នៅចំមុខប្រាសាទមានក្លោងទ្វារ និងមានជណ្តើរមួយទៀត សាង សង់តាំងពីសម័យកសាងប្រាសាទដែលភ្ជាប់ទៅប្រាសាទសែននិមល និង ប្រាសាទភូរាំង និងទន្លេអុំ ដែលជាបឹងកាលពីអតីតកាល ដែលគេចាត់ទុកជា បឹងដ៏ពិសិដ្ឋ សំរាប់ធ្វើពិធីផ្ងូតទឹកលាងបាបតាមលទ្ធិព្រាហ្មណ៍សាសនា។ ក្រៅ ពីនេះនៅមានប្រាសាទជាច្រើនទៀតដ៏ទូលាយ បែរមុខទៅទិសខាងកើត និង ពាយ័ព្យ មានបណ្តោយប្រវែង**១០០ម** និង **ទទឹង៨០ម។** មួយផ្នែកធំនៃប្រាសាទ ភ្នំជីសូរត្រូវបានខូចខាត។

នៅប៉ែកខាងត្បូងនៃប្រាសាទ មានព្រះវិហារពុទ្ធសាសនាសង់ថ្មី មួយ និងនៅខាងក្រោយ មានសាលាធម្មសភាមួយខ្នងដែលមានកុដិព្រះសង្ឃ និងមានទីសក្ការៈតូចមួយទៀត ហើយមានអាងទឹកចំណាស់មួយធ្វើអំពីបេតុង ជាថ្នាក់ៗ។

ភ្នំជីសូរ ជារមណីដ្ឋានទេសចរណ៍ ប្រវត្តិសាស្ត្ររបស់ខេត្តតាកែវ។ មណ្ឌលនេះបាន និង កំពុងឆ្លុះបញ្ចាំងនូវប្រាសាទបុរាណដែលមានកេរ្តិ៍ ដំណែលវប្បធម៌ អរិយធម៌បេតិកភ័ណ្ឌជាតិខ្មែរ គួបផ្សំនឹងទស្សនីយភាពធម្ម ជាតិ និងសមិទ្ធិផលសង្គមផ្សេងៗទៀតក្នុងនោះមានជាអាទិ៍ គឺវត្តភ្នំជីសូរ។ ក្រៅពីប្រាសាទគេឃើញមានវត្តភ្នំជីសូរបានកសាងក្នុងឆ្នាំ១៩១៧ដែលមាន ចៅអធិការវត្តគ្រប់គ្រងតាំងពីដើមរៀងមកមានចំនួន៥អង្គ។ វត្តនេះត្រូវបាន បំផ្លិចបំផ្លាញខ្ទេចខ្ទីក្នុងសង្គ្រាមឆ្នាំ១៩៧០ ហើយចាប់ផ្តើមកសាងជាថ្មីក្នុង ឆ្នាំ១៩៧៩តរៀងមក។

តំបន់កសិទេសចរណ៍ ហ៊ុន សែន ភ្នំជីសូរស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកបាទី និងស្រុកព្រៃកប្បាស ដែលមានវាលស្រែធំល្វឹងល្វើយ និង ប្រព័ន្ធ ធារាសាស្ត្រខ្នាតខ្លែង ក្នុងទំហំ៥១៣ហិចតា និង ស្រះសេវស្បា ១៣៨៦ហិចតា ដែលមានអាងទឹកបីកន្លែងជាប់ៗគ្នា គឺផ្ទស់តាគង់ ទួលលក និងសែនពារាម។



ដើមឈើ ក្នុងបរិវេនប្រាសាទភ្នំជីសូរ





ប្រាសាទភ្នំជីសូរ



ស្រះបុរាណ ក្នុងបរិវេនប្រាសាទភ្នំជីសូរ

ប្រាសាទភ្នំជីសូរ បានកសាងនៅលើកំពូលភ្នំមួយមិនឆ្ងាយពីរាជធានីភ្នំពេញ ដែលមានទេសភាពដ៏ស្រស់ស្អាតជាមួយនឹងវាលស្រែបៃតងនៅនៃភាគខាងត្បូងប្រទេស។ ប្រាសាទតូចមួយនេះបានបង្ហាញពីរចនាបទរបស់សាសនា ហិណ្ឌូ ដែលបានកសាងមុនប្រាសាទអង្គរ ១០០ឆ្នាំ។ ហើយប្រាសាទនេះក៏ជាកន្លែងដែលលោក Matt Dillon យកមកថតខ្សែភាពយន្ត "City of Ghosts" កាលពីឆ្នាំ ២០១២ កន្លងទៅ។

សម្រាប់ព្រះសង្ឃដែលរស់នៅលើភ្នំជីសូរនេះ មានភាពរាក់ទាក់ដូចជាក្មេងៗដែលជាអ្នករកកំរៃដោយសែងភ្ញៀវទេសចរណ៍ឡើងនិងចុះតាមជណ្តើរបុរាណ។

ដើម្បីទៅដល់ទីនោះលោកអ្នកត្រូវជួលតាក់ស៊ី ហើយនឹងអ្នកបើកបរសម្រាប់រយៈពេលកន្លះថ្ងៃដើម្បីទៅកាន់ភ្នំជីសូរ ដោយត្រូវចំណាយប្រមាណជា ២០ដុល្លារ។ ឬក៏អ្នកអាចជួលម៉ូតូដោយចំណាយ ៥ដុល្លារក្នុងមួយថ្ងៃដោយធ្វើដំណើរទៅតាមផ្លូវជាតិលេខ ពីរ ភាគខាងត្បូងនៃខេត្តតាកែវបន្ទាប់មកបត់ឆ្វេង ដោយធ្វើដំណើរចម្ងាយផ្លូវ ៥២គីឡូម៉ែត្រ ហើយអ្នកត្រូវបន្តធ្វើដំណើរតាមផ្លូវលំក្រាលក្រួសក្រហមចម្ងាយ ៤ គីឡូទៀតដើម្បីទៅដល់ជើងភ្នំ និងត្រូវចំណាយលើសំបុត្រចំនួន ២ ដុល្លារសម្រាប់ជនបរទេស។

## ៧. ប្រាសាទសែននិមល

នៅពេលលោកអ្នកឈរចំពីមុខ ប្រាសាទភ្នំជីសូរពីទិសខាងកើតរួចសម្លឹងមើលចំទិសខាងកើត យើងនឹងឃើញមានប្រាសាទចំនួនពីរ គឺប្រាសាទសែននិមល និងប្រាសាទភូវាំង។ យើងអាចចុះតាមជណ្តើរបូរាណមានចម្ងាយជាង ៥០០ម៉ែត្រ ប្រាសាទនេះបានបាក់បែកខូតខាតអស់ច្រើនហើយមានដើមឈើជុំវិញទីធ្លាប្រាង្គប្រាសាទ និងក្នុងតួប្រាសាទ ដូច្នេះយើង

មិនចូលទស្សនាលេង ក្នុងប្រាសាទនេះបានទេ ប៉ុន្តែយើងអាចឈរពីក្រៅ គន់គយភាពស្រស់ស្អាតនៃប្រាង្គប្រាសាទនេះដោយរីករាយ។ បើយើងឈរពីខាងក្រោយនៃប្រាសាទសែននិមលនេះ រួចមើលចំទិសខាងលិចសម្លឹងពីជើងភ្នំតាមកាំជណ្ដើរ បុរាណបាញ់ក្អែកត្ដោះឡើងលើ យើងនឹងបានឃើញប្រាសាទភ្នំជីសូរយ៉ាងស្រស់សោភាពីលើភ្នំ។





ប្រាសាទសែននិមល ត្រូវព្រៃឈើឡោមព័ទ្ធ



ផ្នែកខាងក្រោយនៃប្រាសាទសែននិមល ទិស

## ៨. ប្រាសាទភ្នំវាំង

នៅពេលយើងចំពីមុខនៃប្រាសាទសែន យើងនឹងឃើញផ្លូវលំមួយខ្សែបាញ់ត្រង់មកទិសខាងកើត យើងអាចធ្វើដំណើរតាមផ្លូវនេះ ដោយថ្មើរជើង ជិះកង់ ឬជិះម៉ូតូបានដោយរីករាយ។ យើងធ្វើដំណើរតាមផ្លូវនេះប្រហែលជាង ១០០០ម៉ែត្រ អ្នកទាំងអស់គ្នានឹងបានឃើញប្រាង្គប្រាសាទមួយមានឈ្មោះថា ប្រាសាទភ្នំវាំង។ បើតាមលោកអ៊ំ អ្នកឃ្លាលគោទាំងពីរដែលបាននាំផ្លូវខ្ញុំមកទីនេះបាននិយាយប្រាប់ខ្ញុំថា ប្រាង្គប្រាសាទនេះកសាងតាំងពីសតវត្សទី ០១នៃគ.ស ស្របគ្នានឹងអ្វីដែលលោកអ៊ំទាំងពីរបានលើកឡើង ខ្ញុំមិនអាចស្វែងរកឃើញឯកសារណាពាក់ព័ន្ធនឹងប្រវត្តិនៃប្រាង្គប្រាសាទនេះឡើយ។

ប្រាសាទភ្នំវាំងនេះនូវមានសភាពល្អស្អាតនៅឡើយ យើងអាចដើរទស្សនាមើលប្រាង្គប្រាសាទនេះបានទាំងខាងក្រៅ និងខាងក្នុងដោយរីករាយ ប៉ុន្តែនៅខាងក្នុងចំកណ្ដាលប្រាសាទ យើងឃើញមានគេសាងសង់ជាតូបមួយដែលធ្វើអំពីស៊ីម៉ង់ ក្នុងតូបនេះមានរូបសំណាក់ព្រះពុទ្ធទ្រង់ចូលព្រះនិព្វាន និងនាងសក់ក្រអូប។ បើតាមលោកអ៊ំ អ្នកឃ្លាលគោទាំងបីនាក់បានបញ្ជាក់ថាកាលពីមុនធ្លាប់មានព្រះសង្ឃមួយព្រះគាត់ ទ្រង់មកគង់ចាំព្រះវស្សាក្នុងប្រាង្គប្រាសាទនេះមួយរយៈធំ។ បើយើងឈរចំមុខប្រាសាទភ្នំវាំងនេះ រួចសម្លឹងទៅទិសខាងកើត ហើយធ្វើដំណើរតាមបណ្ដោយផ្លូវដដែលនេះលោកអ្នកនឹងបន្តដំណើរដល់ទន្លេអ៊ុំ។ ជាថ្មីម្ដងទៀត បើសិនលោកអ្នកមកទស្សនាប្រាសាទភ្នំវាំងនេះ គួរតែមកគ្នាច្រើនទើបសប្បាយ ហើយដំណើរកំសាន្តមកទីនេះ ល្អប្រសើរសម្រាប់ដំណើរកំសាន្តបែបបោះជំរុំសំរាកលេង។


ផ្នែកខាងក្រោយនៃប្រាសាទភូរាំង ទិសខាងលិច


ប្រាសាទភូរាំង



ប្រាសាទភូវាំង



ប្រាសាទភូវាំង ឆៀងខាងត្បូង

# ៩. បញ្ហាសកម្មមួយចំនួន

## ៩.១. សំរាម និងថង់ប្លាស្ទិច

ទោះបីជាយ៉ាងណាក៏ដោយ ទាំងប្រាសាទតាព្រហ្ម ប្រាសាទយាយពៅ ទន្លេបាទី និង ប្រាសាទភ្នំជីសូរ ដែលស្ថិតនៅលើកំពូលភ្នំជីសូរក្តី ត្រូវបំផ្លាញសោភ័ណភាពដោយសំរាម និងថង់ប្លាស្ទិច ដែលមានជុំវិញបរិវេទប្រាង្គប្រាសាទ តាមខាងៗព្រះវិហារ តាមជើយមាត់ទឹក និងតាមខាងៗភ្នំជាដើម។ ស្ថានភាពបែបនេះ អាចនឹងធ្វើឲ្យប៉ះពាល់អារម្មណ៍អ្នកទេសចរណ៍លែងចង់មកទស្សនានៅទីនេះម្តងទៀត។ ដូច្នេះទាំងអាជ្ញាធរ ទាំងប្រជាពលរដ្ឋនេះ រួមទាំងអ្នកទេសចរណ៍ទាំងអស់ រួមគ្នាការពារកុំតំបន់នេះមានសំរាម និងថង់ប្លាស្ទិច។

### ដំណោះស្រាយ

<u>វិធីសាស្រ្តខ្លះៗ កុំឲ្យមានសំរាម និងថង់ប្លាស្ទិច</u>

- ផ្លូវច្បាប់
  - បង្កើតច្បាប់ទាក់ទងនឹងថង់ប្លាស្ទិច
  - អ្នកប្រើប្រាស់ថង់ប្លាស្ទិចត្រូវបង់ប្រាក់
  - អ្នកចោលថង់ប្លាស្ទិចត្រូវពិន័យជាប្រាក់ចំនួនច្រើន
- រដ្ឋាភិបាល
  - ក្រសួងបរិស្ថានត្រូវទុកដាក់សំរាមឲ្យបានត្រឹមត្រូវ (បែងចែកតាមប្រភេទនៃសំរាម)
  - លើកទឹកចិត្តឲ្យប្រជាពលរដ្ឋ កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច
  - ផ្តល់ប្រាក់រង្វាស់ដល់អ្នកសកម្មការពារបរិស្ថាន

- បញ្ជូនមន្ត្រីជំនាញ និងសហការជាមួយអង្គការពាក់ព័ន្ធចុះទៅមូលដ្ឋានដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់នៃថង់ប្លាស្ទិច
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយ អំពីផលប៉ះពាល់ និងវិធីសាស្ត្រប្រើប្រាស់ថង់ប្លាស្ទិចឲ្យបានតិចបំផុត
- នៅទីសាធារណៈត្រូវមានធុងសំរាមគ្រប់ទីកន្លែង (បែងចែកតាមប្រភេទនៃសំរាម)
- ត្រូវធ្វើយ៉ាងណាឲ្យមានម៉ាស៊ីនកែច្នៃថង់ប្លាស្ទិច និងសំរាម

**ប្រជាពលរដ្ឋ**

- អប់រំកូនចៅឲ្យចេះការពារបរិស្ថាន
- ត្រូវចូលរួមកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច
- ត្រូវទុកដាក់ថង់ប្លាស្ទិច និងសំរាមឲ្យត្រឹមត្រូវ
- ត្រូវចូលរួមចំណែកការពារបរិស្ថាន
- ការប្រើប្រាស់ឡើងវិញ

## ៩.២. អ្នកសុំថវិកា

ក្នុងប្រាសាទតាព្រហ្ម មានលោកយាយៗ ដែលជាអ្នកសំអាតថែរក្សាប្រាសាទ ច្រើននាក់ពួកគាត់តែងតែតាមសុំថវិកា ពីភ្ញៀវទេសចរណ៍ដែលទៅទស្សនានៅទីនេះ។ សកម្មភាពនេះអាចនឹងធ្វើឲ្យប៉ះពាល់អារម្មណ៍អ្នកទេសចរណ៍ តាមការតាមដារយ៉ាងយកចិត្តទុកដាក់របស់ខ្ញុំ គឺឃើញមានអ្នកទេសចរណ៍ខ្លះ ព្យាយាមដើរគេចពីលោកយាយៗដែលតាមសុំថវិកា។



សំរាមតាមខាងៗ នៃភ្នំជីសូរ



ស្រះទឹកខាងកើត ប្រាសាទតាព្រហ្ម

## ដំណោះស្រាយ

អាជ្ញាធរអប្សរា គួរតែបញ្ជូនភ្នាក់ងារអប្សរាឲ្យចុះមកធ្វើការងារថែរក្សាប្រាង្គប្រាសាទនៅទីនេះ។

ជម្រើស ដ៏ល្អបំផុត គួរតែផ្ដល់ប្រាក់ខែឲ្យលោកយាយៗ ដែលនៅទីនេះស្រេច ឲ្យពួកគាត់ថែរក្សាប្រាង្គប្រាសាទទៅ ប៉ុន្តែកន្លងមកខ្ញុំមិនបានដឹងថា លោកយាយៗនៅទីនេះមានប្រាក់ខែឬអត់?

## ១០. ឯកសារយោង


- ដំណោះស្រាយបញ្ហាជផ្លាស្ទិចនៅកម្ពុជា, និត កុសល កាលពីថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៦
- កំណត់ហេតុនៃការស្រាវជ្រាវ ទន្លេបាទី ប្រាសាទតាព្រហ្ម និងប្រាសាទយាយពៅ, និត កុសល កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៦
- កំណត់ហេតុនៃការស្រាវជ្រាវ ប្រាសាទក្នុងបរិវេណភ្នំជីសូរ ប្រាសាទខ្មៅ និងទន្លេបាទី, និត កុសល កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០៧
- តំបន់ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា, កែវ ភួង  បោះពុម្ពលើកទី២, ២០១៥
- ប្រវត្តិសាស្ត្រខ្មែរ (ភាគរឿងព្រេងនិទាន និងតាមរយៈសិលាចារិក), រស់ ចន្ទ្រាបុត្រ, ១៩៩៧
- https://km.wikipedia.org/wiki/%E1%9E%81%E1%9F%81%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%8F%E1%9E%B6%E1%9E%80%E1%9F%82%E1%9E%9C#.E1.9E.97.E1.9F.92.E1.9E.93.E1.9F.86.E1.9E.87.E1.9E.B8.E1.9E.9F.E1.9E.BC.E1.9E.9A
- http://www.wikiwand.com/km/%E1%9E%81%E1%9F%81%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%8F%E1%9E%B6%E1%9E%80%E1%9F%82%E1%9E%9C#/.E1.9E.91.E1.9E.B8.E1.9E.8F.E1.9E.B6.E1.9F.86.E1.9E.84.E1.9E.97.E1.9E.BC.E1.9E.98.E1.9E.B7.E1.9E.9F.E1.9E.B6.E1.9E.9F.E1.9F.92.E1.9E.9A.E1.9F.92.E1.9E.8F
- https://km.wikipedia.org/wiki/%E1%9E%97%E1%9F%92%E1%9E%93%E1%9F%86%E1%9E%87%E1%9E%B8%E1%9E%9F%E1%9E%BC%E1%9E%9A
- https://tamabloveyaymab.wordpress.com/2012/09/27/phnom-chisor/
- https://km.wikipedia.org/wiki/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F%E1%9E%B6%E1%9E%91%E1%9E%8F%E1%9E%B6%E1%9E%96%E1%9F%92%E1%9E%9A%E1%9E%A0%E1%9F%92%E1%9E%98_(%E1%9E%81%E1%9F%81%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%8F%E1%9E%B6%E1%9E%80%E1%9F%82%E1%9E%9C)